# កូនចៅ

*ដោយ អែលឌើរ នែល អិល អាន់ឌើរសិន*
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

ពេលយើងសម្លឹងមើលភ្នែកក្មេងម្នាក់ យើងមើលឃើញជាបុត្រា ឬបុត្រីម្នាក់នៃព្រះដែលឈរជាមួយយើងក្នុងជីវិតមុនផែនដីនេះ ។

វាជាឯកសិទ្ធិដ៏ធំមួយសម្រាប់ស្វាមីនិងភរិយា ដែលអាចមានកូនដើម្បីផ្តល់រូបកាយរមែងស្លាប់ដល់កូនចៅវិញ្ញាណទាំងនេះនៃព្រះ ។ យើងជឿលើក្រុមគ្រួសារ ហើយយើងជឿលើកូនចៅ ។ ពេលស្វាមីភរិយាមួយគូបង្កើតបានកូនមួយ នោះពួកគេកំពុងតែបំពេញផ្នែកមួយនៃផែនការរបស់ព្រះវរបិតាសួគ៌ដើម្បីនាំកូនចៅទាំងឡាយមកផែនដី ។ ព្រះអម្ចាស់បានមានបន្ទូលថា « នេះហើយជាកិច្ចការរបស់យើង និងសិរីល្អរបស់យើង ---គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ។ [1] ពីមុនមានអមតភាព ត្រូវតែមានជីវិតរមែងស្លាប់ ។

គ្រួសារត្រូវបានតាំងឡើងដោយព្រះ ។ ក្រុមគ្រួសារជាផ្នែកដ៏សំខាន់ក្នុងផែនការរបស់ព្រះវរបិតាសួគ៌នៅលើផែនដីនេះ និងក្នុងភាពអស់កល្ប ។ បន្ទាប់ពីភ្ជាប់ចំណងអ័ដាម និងអេវ៉ាក្នុងអាពាហ៍ពិពាហ៍មក ព្រះគម្ពីរបានចែងថា ៖ « ទ្រង់ប្រទានដល់គេ ហើយមានបន្ទូលថា ចូរបង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដីចុះ » ។ [2] នៅជំនាន់យើង ពួកព្យាការី និងពួកសាវកបានប្រកាសថា « ព្រះបញ្ញត្តិទីមួយដែលព្រះបានប្រទានដល់លោកអ័ដាម និងនាងអេវ៉ា ទាក់ទងទៅនឹងសមត្ថភាពរបស់ពួកគេសម្រាប់ភាពជាឪពុកម្តាយក្នុងនាមជាស្វាមី និងភរិយា ។ យើងសូមប្រកាសថា ព្រះបញ្ញត្តិរបស់ព្រះសម្រាប់កូនចៅរបស់ទ្រង់ ដើម្បីបង្កើតកូនចៅឲ្យចម្រើនជាច្រើនឡើង ឲ្យមានពាសពេញលើផែនដី នោះនៅតែប្រតិបត្តិនៅឡើយ » ។ [3]

ព្រះបញ្ញត្តិនេះមិនត្រូវបានគេបំភ្លេច ឬដាក់ចោលមួយអន្លើក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយឡើយ ។ យើងសូមសម្តែងការដឹងគុណដ៏ជ្រាលជ្រៅចំពោះក្តីជំនឿដ៏ធំធេងដែលបានបង្ហាញដោយស្វាមី និងភរិយាទាំងឡាយ ( ជាពិសេស ភរិយាយើង ) ក្នុងឆន្ទៈរបស់ខ្លួនដើម្បីមានកូន ។ពេលដែលត្រូវមានកូន និងចំនួនកូនដែលចង់បានគឺជាការសម្រេចចិត្តផ្ទាល់ខ្លួនដែលត្រូវធ្វើឡើងរវាងស្វាមី និងភរិយា ហើយនិងព្រះអម្ចាស់ ។ ទាំងនេះជាការសម្រេចចិត្តដ៏ពិសិដ្ឋ ---ជាការសម្រេចចិត្តដែលគួរធ្វើឡើងដោយការអធិស្ឋានដោយស្មោះ ហើយអនុវត្តដោយក្តីជំនឿដ៏រឹងមាំ ។

ច្រើនឆ្នាំកន្លងទៅ  អែលឌើរ ជេមស៍ អូ ម៉ាសិន នៃពួកចិតសិបនាក់បានចែកចាយរឿងនេះជាមួយខ្ញុំថា ៖ « កំណើតកូនទី 6 របស់យើងគឺជាបទពិសោធន៍មួយដែលមិនអាចបំភ្លេចបាន ។ពេលខ្ញុំសម្លឹងមើលកូនស្រីដ៏ស្រស់ស្អាតនេះ ក្នុងកន្លែងមើលក្មេងមួយភ្លែត បន្ទាប់ពីនាងកើត ខ្ញុំបានឮសំឡេងមួយបានប្រកាសយ៉ាងច្បាស់ថា ‹ អ្នកនឹងមានកូនមួយទៀត ហើយវាជាកូនប្រុស › ។ ដោយរៀងឆោតបន្តិច ខ្ញុំក៏ប្រញាប់ត្រឡប់ទៅនៅក្បែរភរិយាខ្ញុំវិញ ដែលគាត់មានការនឿយហត់យ៉ាងខ្លាំង ហើយបានប្រាប់គាត់ពីដំណឹងល្អនោះ ។ វាមិនមែនជាពេលមួយល្អឡើយសម្រាប់ខ្ញុំ ដើម្បីនិយាយរឿងនេះ » ។ [4]

មួយឆ្នាំហើយមួយឆ្នាំទៀត  គ្រួសារ  ម៉ាសិន បានទន្ទឹងចាំការមកដល់នៃកូនទីប្រាំពីរ ។ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរឆ្នាំបានកន្លងផុតទៅ ។ នៅទីបំផុតបន្ទាប់ពីរយៈពេលប្រាំបីឆ្នាំ កូនទីប្រាំពីររបស់ពួកគេបានចាប់កំណើត ---ជាកូនប្រុសតូចមួយ ។ នេះជារូបថតរបស់ពួកគេ 37 ឆ្នាំក្រោយមក ។

កាលពីខែ មេសា ប្រធាន  ថូម៉ាស អេស ម៉នសុន បានប្រកាសថា ៖ « មានពេលមួយ ដែលបទដ្ឋានរបស់សាសនាចក្រ និងបទដ្ឋានរបស់សង្គមស្ទើរតែអាចត្រដុមត្រសងគ្នាបាន តែឥឡូវនេះ មានការខ្វែងគំនិតយ៉ាងធំជាមួយយើង ហើយវារីកកាន់តែធំឡើងៗ ។ ព្រះអង្គសង្គ្រោះនៃមនុស្សលោក បានពណ៌នាពីអង្គទ្រង់ថា នៅក្នុងលោកិយ តែមិនមែនជារបស់លោកិយទេ ។ យើងក៏អាចនៅក្នុងលោកិយ តែមិនមែនជារបស់លោកិយផងដែរ ពេលយើងបដិសេធគំនិត និងការបង្រៀនខុសឆ្គង ហើយបន្តពិតចំពោះអ្វីដែលព្រះបានដាក់បញ្ជា » ។ [5]

សំឡេងជាច្រើនក្នុងពិភពលោកសព្វថ្ងៃមិនយកចិត្តទុកដាក់ពីសារៈសំខាន់នៃការមានកូន ឬណែនាំឲ្យពន្យារពេល ឬកំណត់ចំនួនកូនក្នុងគ្រួសារមួយ ។ ថ្មីៗនេះកូនស្រីខ្ញុំបានប្រាប់ខ្ញុំពីកំណត់ហេតុបណ្តាញមួយដែលសរសេរដោយម្តាយម្នាក់ជាគ្រីស្ទាន ( មិនមែនជាសាសនាយើង ) ហើយមានកូនប្រាំនាក់ ។គាត់ឲ្យយោបល់ថា ៖ « [ ការធំដឹងក្តី ] ឡើងក្នុងវប្បធម៌នេះ វាជាការលំបាកខ្លាំងណាស់ក្នុងការទទួលទស្សនវិស័យពីភាពជាម្តាយក្នុងព្រះគម្ពីរប៊ីប ... ។

ការមានកូនត្រូវបានកំណត់ថ្នាក់ទាបជាងការរៀននៅមហាវិទ្យាល័យ ។ការមានកូនគឺនៅក្រោមការដើរកម្សាន្ត ។ គឺនៅក្រោមសមត្ថភាពដើម្បីចេញទៅលំហែនៅពេលយប់របស់អ្នក ។ គឺក្រោមការពង្រឹងរូបកាយអ្នកនៅកន្លែងហាត់ប្រាណ ។ គឺក្រោមរាល់ការងារដែលអ្នកមាន ឬសង្ឃឹមនឹងទទួលបាន » ។រួចហើយគាត់បានបន្ថែមទៀតថា ៖ « ភាពជាម្ដាយពុំមែនជាការកម្សាន្តឡើយ វាជាការហៅមួយ ។ អ្នកមិនមែនសន្សំទុកកូនចៅនោះទេ ពីព្រោះអ្នកឃើញថាពួកគេស្រស់ស្អាតជាងតែម ។ វាមិនមែនជាអ្វីមួយដែលត្រូវធ្វើឡើយ បើអ្នកអាចដាក់បញ្ចូលពួកគេក្នុងកាលវិភាគដ៏មមាញឹករបស់អ្នកនោះ ។ វាជាអ្វីដែលព្រះផ្ដល់ពេលវេលាដល់អ្នក » ។ [6]

ការមានកូនតូចៗពុំមែនជារឿងងាយស្រួលឡើយ ។ មានការលំបាកជារៀងរាល់ថ្ងៃ ។ មានម្ដាយវ័យក្មេងម្នាក់ឡើងជិះឡានក្រុងមួយជាមួយនឹងកូនទាំងប្រាំពីរនាក់របស់នាង ។អ្នកបើកឡានក្រុងបានសួរថា ៖ « ក្មេងទាំងនេះជាកូនអ្នក ? ឬអ្នករៀបចំការដើរកម្សាន្តមួយមែនទេ ? » នាងបានឆ្លើយថា « ពួកគេជាកូនខ្ញុំ ។ ពុំមែនជាការដើរកម្សាន្តនោះទេ ! » [7]

ខណៈដែលលោកិយនេះចោទសួរកាន់តែខ្លាំងឡើងថា « ក្មេងទាំងនេះជាកូនអ្នកឬ ? » សូមអរគុណអ្នកសម្រាប់ការបង្កើតជម្រកមួយសម្រាប់គ្រួសារក្នុងសាសនាចក្រ ជាកន្លែងដែលយើងមានកិត្តិយសនឹងជួយដល់ម្ដាយដែលមានកូនច្រើន ។

ចំពោះឪពុកដ៏សុចរិតម្នាក់ គ្មានពាក្យណាមួយនឹងថ្លែងដើម្បីសម្ដែងការដឹងគុណ និងក្ដីស្រឡាញ់ដែលគាត់មានចំពោះអំណោយទានដែលមិនអាចវាស់វែងបានក្នុងការបង្កើត និងថែទាំកូនចៅដែលភរិយាខ្លួនមានឡើយ ។

អែលឌើរ ម៉ាសិន មានបទពិសោធន៍មួយទៀត គឺប៉ុន្មានសប្ដាហ៍ក្រោយពីគាត់រៀបការ ដែលបានជួយគាត់ឲ្យរៀបចំអាទិភាពសម្រាប់ទំនួលខុសត្រូវរបស់គាត់ក្នុងគ្រួសារ ។ គាត់បាននិយាយថា ៖ « ម៉ារី ហើយនឹងខ្ញុំបានរៀបចំឡើងវិញថា ដើម្បីជួយខ្ញុំឲ្យរៀនចប់សាលាពេទ្យ នាងចាំបាច់ត្រូវតែបន្តធ្វើការតទៅទៀត ។ ទោះជាយ៉ាង នេះពុំមែនជាអ្វីដែលយើង [ ចង់ ] ធ្វើនោះទេ ដូច្នេះការមានកូនត្រូវតែមកតាមក្រោយ ។ [ ខណៈកំពុងមើលទស្សនាវដ្ដីសាសនាចក្រនៅឯផ្ទះឪពុកម្ដាយខ្ញុំ ] ខ្ញុំបានឃើញអត្ថបទមួយរបស់ អែលឌើរ ស្ពែនស៊ើរ ដបុលយូ឴ ឃីមបឺល ពេលនោះលោកក្នុងកូរ៉ុមនៃពួកដប់ពីរនាក់បានលើកឡើង [ ដោយគូសបញ្ជាក់ ] ពីទំនួលខុសត្រូវដែលមាននៅក្នុងអាពាហ៍ពិពាហ៍ ។យោងតាម  អែលឌើរ ឃីមបឺល ទំនួលខុសត្រូវដ៏ពិសិដ្ឋមួយគឺបង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដី ។ ផ្ទះឪពុកម្ដាយខ្ញុំនៅ [ ជិតនឹង ] អគាររដ្ឋបាលសាសនាចក្រ ។រំពេចនោះ ខ្ញុំបានដើរទៅការិយាល័យ ហើយក្រោយពីអានអត្ថបទរបស់គាត់បាន 30 នាទី ខ្ញុំបានរកឃើញថា ខ្លួនឯងកំពុងអង្គុយនៅពីមុខអែលឌើរ ស្ពែនស៊ើរ ដបុលយូ឴ ឃីមបឺល » ។ ( ការណ៍នេះមិនងាយកើតឡើងនៅសព្វថ្ងៃនេះឡើយ ) ។ « ខ្ញុំបានពន្យល់ថា ខ្ញុំចង់ក្លាយជាវេជ្ជបណ្ឌិត ។វាគ្មានជម្រើសឡើយ គឺត្រូវផ្អាកការមានកូនសិន ។  អែលឌើរ ឃីមបឺល បានស្ដាប់ដោយស្ងៀមស្ងាត់ រួចហើយបានឆ្លើយដោយសំឡេងស្រទន់ថា ‹ បងប្រុស  ម៉ាសិន តើព្រះអម្ចាស់ចង់ឲ្យអ្នករំលងព្រះបញ្ញត្តិមួយដ៏សំខាន់របស់ទ្រង់ ដើម្បីឲ្យអ្នកបានក្លាយជាវេជ្ជបណ្ឌិតមែនទេ ? ដោយមានជំនួយពីព្រះអម្ចាស់ អ្នកអាចមានកូន និងបន្តធ្វើជាវេជ្ជបណ្ឌិតម្នាក់បានដដែល ។ តើក្ដីជំនឿអ្នកនៅឯណា ? › »

អែលឌើរ ម៉ាសិន បានបន្តថា ៖ « កូនដំបូងរបស់យើងបានកើតមិនដល់មួយឆ្នាំក្រោយមកផង ។  ម៉ារី ហើយនឹងខ្ញុំបានខិតខំធ្វើការ ហើយព្រះអម្ចាស់បានបើកទ្វារស្ថានសួគ៌ ។ គ្រួសារ ម៉ាសិនបានប្រទានពរឲ្យមានកូនពីរនាក់ទៀត ពីមុនគាត់បញ្ចប់សាលាពេទ្យបួនឆ្នាំក្រោយមក ។ [8]

នៅជុំវិញពិភពលោក នេះជាពេលនៃអស្ថិរភាពខាងសេដ្ឋកិច្ច និងភាពមិនប្រាកដប្រជាខាងហិរញ្ញវត្ថុ ។ ក្នុងសន្និសីទទូទៅខែមេសា ប្រធាន  ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា ៖ « បើអ្នកមានកង្វល់ពីការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុដល់ភរិយា និងគ្រួសារ ខ្ញុំសូមអះអាងដល់អ្នកថា គឺពុំមែនជារឿងដែលគួរឲ្យអាម៉ាស់ ដែលគូស្វាមីភរិយាធ្វើការចាយវាយតិច ហើយសន្សំទុកនោះឡើយ ។ជាទូទៅ វាជាពេលដ៏លំបាកទាំងនេះហើយដែលអ្នកនឹងមានភាពស្និទ្ធស្នាលនឹងគ្នាថែមទៀត ពេលអ្នករៀនលះបង់ ហើយធ្វើការសម្រេចចិត្តដ៏លំបាក » ។ [9]

សំនួរដ៏ឈ្លាសវៃរបស់អែលឌើរ ឃីមបឺល ថា « តើក្ដីជំនឿអ្នកនៅឯណា ? » បាននាំយើងទៅរកព្រះគម្ពីរបរិសុទ្ធ ។ វាពុំមែននៅក្នុងសួនច្បារអេដែនដែលអ័ដាម និងអេវ៉ា មានកូនដំបូងរបស់ពួកគេនោះឡើយ ។ ដោយចាកចេញពីសួនច្បារនោះ « អ័ដាម [ និងអេវ៉ា ] បានចាប់ផ្ដើមភ្ជួររាស់ដី ... ។ អ័ដាមក៏ស្គាល់ប្រពន្ធគាត់ ហើយនាងបង្កើត]បានកូនប្រុសកូនស្រីទាំងឡាយ ហើយ[ ដោយធ្វើដោយក្ដីជំនឿ ]ពួកគេបានចាប់ផ្ដើមបង្កើតកូនជាច្រើនឡើង ហើយមានពេញពាសផែនដី ។ [10]

វាពុំមែនក្នុងផ្ទះឯយេរូសាឡឹម ដែលមានមាស ប្រាក់ និងរបស់មានតម្លៃជាច្រើន ដែលលីហៃ និងសារ៉ាយ ប្រព្រឹត្តដោយក្ដីជំនឿ បង្កើតកូនប្រុសខ្លួន យ៉ាកុប និងយ៉ូសែបនោះទេ ។ វាគឺនៅទីរហោស្ថាន ។ លីហៃបាននិយាយពីកូនប្រុសរបស់គាត់យ៉ាកុបថាជា « កូនច្បងរបស់ឪពុកដែលបានកើតនៅក្នុងថ្ងៃ

នៃសេចក្តីវេទនារបស់ឪពុកក្នុងទីរហោស្ថាន » ។ [11] លីហៃបាននិយាយពីយ៉ូសែបថា « កូនបានកើតនៅក្នុងទីរហោស្ថាននៃសេចក្តីទុក្ខវេទនារបស់ [ យើង ] មែនហើយ នៅក្នុងថ្ងៃដែល[ យើង ] មានទុក្ខសោកយ៉ាងធំ ដែលម្តាយកូនបានបង្កើតកូនមក » ។ [12]

ក្នុងព្រះគម្ពីរនិក្ខមនំ មានបុរសម្នាក់និងស្ត្រីម្នាក់បានរៀបការ ហើយដោយប្រព្រឹត្តដោយក្តីជំនឿ បង្កើតបានកូនប្រុសមួយ ។ គ្មានសញ្ញាស្វាគមន៍នៅពីមុខទ្វារដើម្បីប្រកាសពីកំណើតរបស់ក្មេងនេះឡើយ ។ ពួកគេបានលាក់គាត់ ដោយសារស្តេចផារ៉ោនបានបញ្ជាថា រាល់ក្មេងប្រុសសាសន៍អ៊ីស្រាអែលដែលកើតមក ត្រូវ « បោះចោលទៅក្នុងទន្លេ » ។ [13]

អ្នកដឹងពីដំណើររឿងបន្ទាប់មកទៀត ៖ ទារកនោះត្រូវបានយកទៅដាក់ក្នុងទូកតូចមួយ ធ្វើពីដើមបបុស រួចដាក់បណ្តែតវាទៅក្នុងទន្លេ ឯបងស្រីក្មេងនោះក៏ឈរចាំមើល ក្មេងនោះត្រូវបានកូនស្រីរបស់ស្តេចផារ៉ោនរកឃើញ ហើយត្រូវបានមើលថែដោយម្តាយបង្កើតរបស់ខ្លួន ក្នុងនាមមេដោះ ។ ក្មេងប្រុសនោះបានត្រឡប់ទៅរកកូនស្រីរបស់ផារ៉ោនវិញ ជាអ្នកដែលយកគាត់ធ្វើកូន ហើយហៅគាត់ថាម៉ូសេ ។

នៅក្នុងដំណើររឿងដែលគួរឲ្យជាប់ចិត្តបំផុតនៃកំណើតនៃទារកម្នាក់ គឺគ្មានកន្លែងមើលថែក្មេង ឬគ្រែល្អៗនោះ ---គឺមានតែស្នូកមួយសម្រាប់ព្រះអង្គសង្គ្រោះនៃពិភពលោក ។ ទាំងក្នុង « គ្រាដ៏លំបាក និងគ្រាដ៏រីករាយបំផុត » [14] ពួកបរិសុទ្ធដ៏ពិតនៃព្រះ ដោយប្រព្រឹត្តក្នុងក្តីជំនឿ មិនដែលភ្លេច បោះបង់ចោល ឬបដិសេធនឹង « ព្រះបញ្ញត្តិនៃព្រះសម្រាប់កូនចៅទ្រង់ ដើម្បីបង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដីឡើយ » ។ យើងដើរឆ្ពោះទៅមុខក្នុងក្តីជំនឿជាថ្មីម្តងទៀត ដោយដឹងថាការសម្រេចចិត្តថាតើចង់បានកូនប៉ុន្មាននាក់ ហើយចង់បានពួកគេនៅពេលណានោះគឺរឿងរវាងស្វាមី និងភរិយា ហើយនឹងព្រះអម្ចាស់ ។ យើងមិនគួរវិនិច្ឆ័យគ្នាទៅវិញទៅមកលើបញ្ហានេះឡើយ ។

ការបង្កើតកូនជាប្រធានបទមួយដែលងាយនឹងប៉ះទង្គិចដល់ផ្លូវចិត្តរបស់ស្ត្រីសុចរិត ដែលគ្មានឱកាសនឹងរៀបការ និងមានគ្រួសារ ។ ចំពោះអ្នកដែលជាស្ត្រីដ៏ថ្លៃថ្នូរ ព្រះវរបិតាសួគ៌យើងជ្រាបពីការអធិស្ឋាន និងក្តីប្រាថ្នាអ្នក ។ យើងមានក្តីអំណរអ្វីម្ល៉េះចំពោះឥទ្ធិពលដ៏អស្ចារ្យរបស់អ្នក រួមទាំងការជួយដល់ក្មេងដែលត្រូវការក្តីជំនឿ និងភាពរឹងមាំរបស់អ្នកដោយក្តីស្រឡាញ់ផងដែរ ។

ការបង្កើតកូនក៏អាចជាប្រធានបទមួយដែលប៉ះទង្គិចដល់ដួងចិត្តនៃស្វាមីភរិយាដែលរៀបការ ហើយរកឃើញថា ពួកគេមិនអាចមានកូនដែលពួកគេចង់បានយ៉ាងខ្លាំង ឬនៃស្វាមីភរិយាដែលចង់បានគ្រួសារមួយដ៏ធំ តែត្រូវបានប្រទានឲ្យមានគ្រួសារតូចមួយ ។

យើងមិនអាចពន្យល់ពីការលំបាកក្នុងជីវិតរមែងស្លាប់របស់យើងជានិច្ចបានទេ ។ ពេលខ្លះ ជីវិតហាក់ដូចជាមិនយុត្តិធម៌សោះ ---ជាពិសេសពេលដែលក្តីប្រាថ្នាដ៏ធំបំផុតរបស់យើងត្រូវធ្វើតាមអ្វីដែលព្រះអម្ចាស់បានបញ្ជា ។ ក្នុងនាមជាអ្នកបម្រើរបស់ព្រះអម្ចាស់ ខ្ញុំសូមអះអាងនឹងអ្នកថា ការសន្យានេះគឺពិតប្រាកដមែនថា ៖ « សមាជិកស្មោះត្រង់ដែលមានស្ថានភាពមិនអនុញ្ញាតឲ្យពួកគេទទួលបានពរជ័យទាំងឡាយនៃអាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ច និងភាពជាឪពុកម្តាយនៅក្នុងជីវិតនេះនឹងទទួលគ្រប់ពរជ័យដែលបានសន្យាក្នុងភាពដ៏នៅអស់កល្បជានិច្ច ដរាបណាពួកគេរក្សាសេចក្តីសញ្ញាទាំងឡាយដែលពួកគេបានធ្វើជាមួយនឹងព្រះ » ។ [15]

ប្រធាន ជេ ស្កុត ដ៏វីស នៃបេសកកម្មពេរូលីម៉ាខាងលិចបានប្រាប់ខ្ញុំពីដំណើររឿងពួកគាត់ ។ គាត់បាននិយាយថា « បេិកគី ហើយនិងខ្ញុំបានរៀបការអស់រយៈពេល 25 ឆ្នាំ ដោយគ្មានលទ្ធភាពមានកូន [ឬសុំកូនមកចិញ្ចឹម]បានឡើយ ។ យើងបានផ្លាស់ប្តូរលំនៅជាច្រើនដង ។ការណែនាំខ្លួនយើងក្នុងមជ្ឈដ្ឋានថ្មីនីមួយៗ គឺជារឿងដ៏លំបាក ហើយពេលខ្លះមានការឈឺចាប់ ។ សមាជិកវួដងឿងឆ្ងល់ថាហេតុអ្វីបានជាយើង [ គ្មាន ] កូន ។ ពួកគេពុំមែនជាមនុស្សតែម្នាក់ដែលងឿងឆ្ងល់នោះទេ ។

« ពេលខ្ញុំត្រូវបានហៅជាប៊ីស្សព សមាជិកវួដ [ បានសម្តែង ] នូវកង្វល់ថា ខ្ញុំគ្មានបទពិសោធន៍ណាមួយជាមួយនឹងកុមារ និងក្មេងជំទង់ឡើយ ។ ខ្ញុំបានអរគុណដល់សមាជិកវួដសម្រាប់ការគាំទ្ររបស់ពួកគេ ហើយសុំអនុញ្ញាតពួកគេឲ្យខ្ញុំបានអនុវត្តជំនាញចិញ្ចឹមបីបាច់កូនជាមួយនឹងកូនរបស់ពួកគេ ។ ពួកគេបានអនុញ្ញាតដោយក្តីស្រឡាញ់ ។

« យើងបានរង់ចាំ បានទទួលទស្សនវិស័យ ហើយបានរៀនអត់ធ្មត់ ។ បន្ទាប់ពីរៀបការបាន 25 ឆ្នាំ កូនម្នាក់បានកើតមានក្នុងជីវិតយើងជាអព្ភូតហេតុមួយ ។ យើងបានសុំ នីកូល អាយុពីរឆ្នាំ រួចហើយ នីកូឡៃ ដែលទើបនឹងកើតមកចិញ្ចឹម ។ ឥឡូវនេះពួកមនុស្សចម្លែកបានសរសើរយើងពីចៅដ៏ស្រស់ស្អាតរបស់យើង ។ យើងសើច ហើយនិយាយថា ‹ ពួកគេជាកូនចៅយើង ។ យើងបានរស់នៅក្នុងជីវិត ថយក្រោយ › » ។ [16]
បងប្អូនប្រុសស្រី យើងមិនគួរវិនិច្ឆ័យគ្នាទៅវិញទៅមកក្នុងទំនួលខុសត្រូវផ្ទាល់ខ្លួន ហើយពិសិដ្ឋនេះឡើយ ។

« រួច [ ព្រះយេស៊ូវ ] បីវា មានបន្ទូលទៅគេថា « អ្នកណាដែលទទួលកូនតូចមួយដូចជាកូននេះដោយនូវឈ្មោះខ្ញុំ នោះក៏ឈ្មោះថាទទួលខ្ញុំ ហើយអ្នកណាដែលទទួលខ្ញុំ...គឺឈ្មោះថាទទួលព្រះដែលបានចាត់ឲ្យខ្ញុំមក » [17] យើងមានពរជ័យមួយអស្ចារ្យណាស់ ដើម្បីទទួលបានបុត្រាបុត្រីនៃព្រះចូលក្នុងផ្ទះរបស់យើង ។

ចូរយើងស្វែងរកដោយរាបសា និងប្រកបដោយការអធិស្ឋាន ដើម្បីយល់ និងទទួលយកព្រះបញ្ញត្តិរបស់ព្រះ ដោយស្តាប់សំឡេងពីព្រះវិញ្ញាណបរិសុទ្ធដោយគារវភាព ។

ក្រុមគ្រួសារគឺជាផ្នែកដ៏សំខាន់ក្នុងផែនការដ៏អស់កល្បរបស់ព្រះ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ពីពរជ័យដ៏ធំនៃកូនចៅនេះ និងពីសុភមង្គលដែលពួកគេនាំមកឲ្យយើងក្នុងជីវិតនេះ និងក្នុងភាពអស់កល្ប ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។

កំណត់ចំណាំ

1. ម៉ូសេ 1:39 ។
2. លោកុប្បត្តិ 1:28 ។
3. « The Family: A Proclamation to the World » *Liahona* និង *Ensign* Nov. 2010 ទំព័រ 129 ។
4. អ៊ីម៉ែលទទួលបានពីអែលឌើរ James O. Mason ថ្ងៃទី 25 ខែ មិថុនា ឆ្នាំ 2011 ។
5. ថូម៉ាស អេស ម៉នសុន « អំណាចបព្វជិតភាព » លីអាហូណា ខែ ឧសភា ឆ្នាំ 2011 ទំព័រ 66, 67 ។
6. Rachel Jankovic « Motherhood Is a Calling (and Where Your Children Rank) » ថ្ងៃទី 14 ខែ កក្កដា ឆ្នាំ 2011, desiringgod.org
7. សូមមើល thejokes.co.uk/jokes-about-children.php ។
8. អ៊ីម៉ែលទទួលបានពីអែលឌើរ James O. Mason ថ្ងៃទី 29 ខែ មិថុនា ឆ្នាំ 2011 ។
9. ថូម៉ាស អេស ម៉នសុន *លីអាហូណា* ខែ ឧសភា ឆ្នាំ 2011 ទំព័រ 67 ។
10. ម៉ូសេ 5:1--2 ។
11. នីហ្វៃទី2 2:1 ។
12. នីហ្វៃទី2  3:1 ។
13. និក្ខមនំ 1:22 ។
14. Charles Dickens, *A Tale of Two Cities* (Signet Classic, 1997)ទំព័រ 13 ។
15. *ក្បួនខ្នាតភាគ 2 ៖ ការគ្រប់គ្រងសាសនាចក្រ* (2010) ចំណុច 1.3.3 ។
16. ការសន្ទនាផ្ទាល់ជាមួយនឹងប្រធាន J. Scott Dorius ថ្ងៃទី 28 ខែ សីហា ឆ្នាំ 2011 ។
17. ម៉ាកុស 9:36--37 ។